**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំពិគ្រោះយោបល់
## "របាយការណ៍នៃការចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ"

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ - ក្រសួងបរិស្ថានបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធ សរុបប្រមាណ ១២០នាក់ អំពី **របាយការណ៍នៃការចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDC កម្ពុជា)** នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្រោមអធិបតីភាពរបស់ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ របាយការណ៍នៃការចូលរួមចំណែកនេះ គឺជាឯកសារដ៏សំខាន់មួយដែលបញ្ជាក់អំពីការរួមចំណែករបស់ភាគីកម្ពុជាក្នុងការឆ្លើយតបនឹងសេចក្តីអំពាវនាវរបស់អនុសញ្ញានេះ ក្នុងគោលបំណងជំរុញឱ្យពិភពលោកធ្វើសកម្មភាពដោះស្រាយការប្រែប្រួលអាកាសធាតុ ដែលនឹងត្រូវបញ្ជូនទៅកាន់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅមុនពេលកិច្ចប្រជុំកំពូលបណ្តាភាគីលើកទី២១ នៅទីក្រុងប៉ារីស ប្រទេសបារាំង នាខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ។

ថ្លែងនៅក្នុងពិធីបើក ឯកឧត្តមរដ្ឋមន្ត្រី **សាយ សំអាល់** បានមានប្រសាសន៍ថា "ក្នុងនាមជាប្រទេសបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចតួច ប៉ុន្តែងាយទទួលរងគ្រោះខ្លាំងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចនេះការរួមចំណែករបស់កម្ពុជា ចាំបាច់ត្រូវតែបន្សីុជាមួយអាទិភាពអភិវឌ្ឍន៍របស់ប្រទេស។ របាយការណ៍ INDC កម្ពុជា នឹងរួមបញ្ចូលសមាសភាគបន្សាំ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដោយផ្អែកលើស្ថានភាពប្រទេសជាតិ និងបន្សីុជាមួយសេចក្តីសម្រេចរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ 1/CP.19 និង 1/CP.20"។

ឯកឧត្តមបានបន្តថា "នេះជាជំហានថ្មីដ៏សំខាន់មួយទៀតរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្ហាញពីឆន្ទៈចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុជាមួយសហគមន៍អន្តរជាតិ ដើម្បីឆ្ពោះទៅរកការសម្រេចបាននូវកិច្ចព្រមព្រៀងអាកាសធាតុថ្មីមួយនៅឆ្នាំ២០១៥"។

តាមរយៈកិច្ចពិគ្រោះយោបល់ជាបន្តបន្ទាប់ របាយការណ៍ចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ មាន៥ផ្នែក ដូចខាងក្រោម៖

- ផ្នែកទី១៖ **បរិបទជាតិ** បង្ហាញអំពីបច្ចុប្បន្នភាពជាតិ ដែលទាក់ទងនឹងការចូលរួមចំណែកនេះ។
- ផ្នែកទី២៖ **បន្សាំ** បង្ហាញអំពីភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ និងសកម្មភាពបន្សាំអាទិភាព។
- ផ្នែកទី៣៖ **ការកាត់បន្ថយ** បង្ហាញអំពីការរួមចំណែករបស់កម្ពុជា ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយមានសេចក្តីពន្យល់ ដើម្បីធានាបាននូវភាពច្បាស់លាស់ និងការប្រៀបធៀប និងការពន្យល់អំពីភាពយុត្តិធម៌ និងមហិច្ឆិតា។

ផ្នែកទី៤៖ **ដំណើការរៀបចំផែនការ និងអនុវត្តន៍** ដោយមានសូចនាករផ្នែកស្ថាប័ន គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានាដែលនឹងគាំទ្រការអនុវត្ត INCD នៅកម្ពុជា។

ផ្នែកទី៥៖ **មធ្យោបាយអនុវត្តន៍** ដោយមានព័ត៌មានអំពីការគាំទ្រចាំបាច់សម្រាប់អនុវត្តការចូលរួមនេះ។

គួរបញ្ជាក់ផងដែរថា កម្ពុជាបានចាប់ផ្តើមរៀបចំ INDC របស់ជាតិ ដោយមានការសម្របសម្រួលពីនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន ក្រោមការគាំទ្រសហការពីស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅកម្ពុជា និងមូលនិធិបរិស្ថានពិភពលោកតាមរយៈកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)។ ការរៀបចំរបាយការណ៍នេះនឹងត្រូវបញ្ចប់ និងដាក់ជូនលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនាខែតុលា ឆ្នាំ២០១៥។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ឯកឧត្តម **សៅ សុភាព** នាយកខុទ្ទកាល័យ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន តាមរយៈលេខទូរស័ព្ទ ០១២ ៩៧១ ២២២ ឬ saosopheap@yahoo.com។

-------------------//ចប់//--------------------

**កំណត់សម្គាល់៖**

**១) តើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ គឺជាអ្វី?**

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានអនុម័តនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩២ នៅទីក្រុងញូវយ៉ក និងបានចុះហត្ថលេខានៅក្នុងកិច្ចប្រជុំកំពូលពិភពលោក ឆ្នាំ១៩៩២ នៅទីក្រុងរីយ៉ូដឺហ្សានេរ៉ូ ប្រទេសប្រេស៊ីល ដោយប្រទេសជាង១៥០ និងសហគមន៍អឺរ៉ុប។ គោលបំណងចម្បងនៃអនុសញ្ញានេះគឺ "ធ្វើឱ្យមានស្ថិរភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស នៅត្រឹមកម្រិតមួយដែលអាចទប់ស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់ពីសកម្មភាពមនុស្សមកលើប្រព័ន្ធអាកាសធាតុ"។ អនុសញ្ញានេះចែងអំពីការប្តេជ្ញាចិត្តរបស់បណ្តាភាគីទាំងអស់។ អនុសញ្ញានេះ ចូលជាធរមាននៅខែមីនា ឆ្នាំ១៩៩៤។ នៅឆ្នាំ១៩៩៧ អនុសញ្ញានេះបានអនុម័តឱ្យមានពិធីសារក្យូតូ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩៥ ក្រោយពីការបង្កើតក្រសួងបរិស្ថានបានពីរឆ្នាំ។

**២) តើការចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Cambodia's INDC) គឺជាអ្វី?**

នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បណ្តាប្រទេសទូទាំងពិភពលោក បានប្តេជ្ញាចិត្តបង្កើតកិច្ចព្រមព្រៀងអាកាសធាតុអន្តរជាតិថ្មីមួយ ដែលនឹងត្រូវបូកសរុបនៅក្នុងសន្និសីទកំពូលបណ្តាភាគីលើកទី២១ នៃUNFCCC នៅទីក្រុងប៉ារីស ខែធ្នូ ឆ្នាំ២០១៥។ ក្នុងការរៀបចំរបាយការណ៍នេះ បណ្តាប្រទេសនានា បានឯកភាពបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិថ្មីមួយ ហៅថា "ការចូលរួមចំណែកក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDC)"។ ការរួមចំណែកជាសកលនេះ បាននាំមកនូវអភិក្រមពីថ្នាក់ក្រោមទៅលើ ដើម្បីរៀបចំគោលជំហររបស់ប្រទេសដោយផ្អែកលើស្ថានភាពជាតិតាមប្រព័ន្ធថ្នាក់ជាតិ ដើម្បីកាត់បន្ថយកំណើនសីតុណ្ហភាពមធ្យមរបស់សកលលោកត្រឹម ២អង្សាសេ។ ប្រទេសកម្ពុជាទទួលស្គាល់តម្រូវការឱ្យប្រទេសទាំងអស់ចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហើយដើម្បីរួមចំណែកសម្រេចនូវគោលដៅនេះ ប្រទេសកម្ពុជាមានក្តីសោមនស្សក្នុងការរៀបចំរបាយការណ៍នៃការចូលរួមចំណែករបស់ខ្លួនក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDC) ឱ្យបានមុនកិច្ចប្រជុំបណ្តាភាគីលើកទី២១ នៅទីក្រុងប៉ារីស។

Kingdom of Cambodia
Nation Religion King

Ministry of Environment

Phnom Penh, 16 September 2015

# Press Release

## Consultation Meeting
## "Cambodia's Intended Nationally Determined Contribution"

Phnom Penh, 16 September 2015 - The Ministry of Environment organized a consultation meeting on **Cambodia's Intended Nationally Determined Contribution (Cambodia's INDC)** attended by approximately 120 representatives from line ministries/agencies, development partners and key stakeholders at Himawari hotel, presided over by **H.E. Say Samal**, the Minister of Environment. The Cambodia's INDC is one of the main documents presenting Cambodia's contribution to the globe's Call for Climate Action to be submitted to UNFCCC-Secretariat, a head of COP 21 in Paris of France in coming December 2015.

Delivering the opening remarks, **H.E. Say Samal**, the Minister of Environment, mentioned the country's contribution that "As a low emitter and highly vulnerable country to the negative effects of climate change, our contribution is necessarily aligned with our development priorities. The INDC therefore includes both adaptation and mitigation components based on our national circumstances, and in line with UNFCCC decisions 1/CP.19 and 1/CP.20".

"This is another major step of the royal government, showing commitments with the international community to tackle climate change towards achieving a new climate agreement in 2015", added by His Excellency Minister.

Through the various consultations, Cambodia's INDC consists of 5 sections as follow:

- Section 1: **The national context**, where we present our national circumstances as they relate to the INDC;
- Section 2: **Adaptation**, in which we illustrate our vulnerability to climate change and the prioritized adaptation actions;
- Section 3: **Mitigation**, where we present our intended contribution to reduce greenhouse gas emissions, with explanations to ensure clarity and comparability, and illustration of fairness and ambition;
- Section 4: **Planning and implementation processes**, with indications of the institutions, policies, strategies, and plans that will support the implementation of the INDC in Cambodia;
- Section 5: **Means of implementation**, with information on the support needed for the implementation of the INDC.

Cambodia has been preparing INDC coordinating by Department of Climate Change of the Ministry of Environment under the collaborative support of the British Embassy in Cambodia and the Global Environment Facility (GEF) through United Nations Environmental Programme (UNEP). The preparation of this report will be completed and submitted to the UNFCCC Secretariat by October 2015 in prior to Conference of Parties 21 to be hosted in coming December in Paris.

For more information, kindly contact **H.E. Sao Sopheap**, Chief of the Minister's Cabinet and spoke person through 012 971 222 or saosopheap@yahoo.com.

**Notes to Editors:**

**1) What is United Nations Framework Convention on Climate Chang (UNFCCC)?**

The Convention was adopted on 9 May 1992 in New York and signed at the 1992 Earth Summit in Rio de Janeiro by more than 150 countries and the European Community. Its ultimate objective is the "stabilization of greenhouse gas concentrations in the atmosphere at a level that would prevent dangerous anthropogenic interference with the climate system". It contains commitments for all Parties. The Convention entered in force in March 1994. In 1997, the UNFCCC adopted the Kyoto Protocol. Cambodia signed the UNFCCC on 13 December 1995, just two years after the establishment of the Ministry of Environment

**2) What is Cambodia's Intended Nationally Determine Contribution (Cambodia's INDC)?**

Under the U.N. Framework Convention on Climate Change (UNFCCC), all countries across the globe made a commitment to develop a new international climate agreement by the conclusion of the Paris Climate Summit in December 2015. During previous climate negotiations, countries agreed to outline their commitments to reducing greenhouse gas emissions under a global agreement, with the so-called **Intended Nationally Determined Contributions (INDCs)**. These global contributions bring together bottom-up approaches, where countries put forward their positions based on national circumstances, with a top-down system aimed at reducing the average global temperature to 2$^{o}$C.

Cambodia recognises the need for all countries to limit their greenhouse gas emissions, in order to achieve the UNFCCC's objective. To successfully contribute to this global goal, we are extremely pleased to present our Intended Nationally Determined Contribution (INDC) to the United Nations Framework Convention on Climate Change (UNFCCC), ahead of COP 21 in Paris.